# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតរដ្ឋាករទឹកស្វយ័តសៀមរាប ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃ ទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៦ ។

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.** -

ត្រូវបានកែប្រែអង្គភាពរដ្ឋាករទឹកសៀមរាប ឱ្យទៅជាគ្រឹះស្ថានសាធារណៈមួយដែលមានលក្ខណៈសេដ្ឋកិច្ច ដែលមានឈ្មោះថា **រដ្ឋាករទឹកស្វយ័តសៀមរាប** សរសេរកាត់ " រ ស ស "។

រ ស ស ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយមានទីស្នាក់ការនៅ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។

រ ស ស គឺជានីតិបុគ្គលប្រកបដោយស្វ័យភាពផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ។

**មាត្រា ២.** -

រ ស ស មានបេសកកម្មផលិត ផ្គត់ផ្គង់ និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ជាទូទៅនៃសាធារណជននៅទីរួមខេត្តសៀមរាប និងនៅទីប្រជុំជនជុំវិញទីរួមខេត្ត ។

ដើម្បីបំពេញបេសកកម្មនេះ រ ស ស ត្រូវបានអនុញ្ញាតឱ្យធ្វើកិច្ចប្រតិបត្តិការគ្រប់ជំពូកលើអចលនវត្ថុ ព្រមទាំងកិច្ចប្រតិបត្តិការលើផ្នែកពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ដែលមានជាអាទិ៍ ÷

- ការផលិត ការផ្គត់ផ្គង់ និងចែកចាយទឹកស្អាតទូទៅ ក្នុងទីរួមខេត្តសៀមរាប និងនៅទីប្រជុំជនជុំវិញទីរួមខេត្ត
- ការបង្កើនសមត្ថភាពផលិតព្រមទាំងការពង្រីក និង ការស្តារឡើងវិញនូវប្រព័ន្ធផលិត និង បណ្តាញផ្គត់ផ្គង់ និងចែកចាយទឹកស្អាត
- ការធ្វើអាជីវកម្មលើបណ្តាញផ្គត់ផ្គង់ និងចែកចាយទឹកស្អាត ដែលមានស្រាប់ ឬ ត្រូវបង្កើតថ្មី ។

**មាត្រា ៣.** -

ភ្នាក់ងារ រ ស ស មានសិទ្ធិចេញចូលក្នុងទីកន្លែងសាធារណៈ ឬទីលំនៅឯកជនតាមតម្រូវការងាររបស់ខ្លួន ដើម្បីធ្វើការងារដំឡើង ជួសជុលបំពង់ទឹក ត្រួតពិនិត្យផ្នែកបច្ចេកទេសគ្រឿងម៉ាស៊ីន ផលិតកម្ម និង បណ្តាញផ្គត់ផ្គង់ និងចែកចាយទឹកស្អាត ហើយនិងកត់ត្រាបរិមាណទឹកស្អាត ដែលបានប្រើប្រាស់ ដោយត្រូវមានឯកសណ្ឋានសម្គាល់ និងត្រូវបង្ហាញប័ណ្ណអាជីវកម្មយថាភូតរបស់ខ្លួន ។

**មាត្រា ៤.-**

ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន រ ស ស ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នានឹង ពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ រ ស ស ត្រូវទទួលស្វយ័តភាពយ៉ាងធំទូលាយដើម្បីដឹកនាំចាត់ចែង សកម្មភាពរបស់ខ្លួន ក្នុងគោលដៅបំពេញបេសកកម្មឱ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឱ្យបេតិកភ័ណ្ឌ របស់ខ្លួនបានគង់វង្ស និងមានការរីកចម្រើន។

**មាត្រា ៥.-**

រ ស ស ត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិដូចតទៅ :

១- ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាស សាធារណៈ

២- អនុក្រឹត្យស្តីពីការបង្កើត **រដ្ឋាករទឹកស្វយ័តសៀមរាប**

៣- លក្ខន្តិកៈ **រដ្ឋាករទឹកស្វយ័តសៀមរាប**

៤- ច្បាប់ និងបទបញ្ជាពាក់ពន្ធ័ក្រុមហ៊ុនពាណិជ្ជកម្ម ។

**មាត្រា ៦.-**

រ ស ស ត្រូវបង់ពន្ធអាករទាំងឡាយ ស្របតាមច្បាប់ និងបទបញ្ជាជាធរមាន ។

**មាត្រា ៧.-**

ដើមទុនដំបូងរបស់ រ ស ស ត្រូវកំណត់ដោយបញ្ជីតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ចាប់ពីពេលដែលអនុក្រឹត្យនេះចូលជាធរមាន រ ស ស ត្រូវចាត់ទុកថា ជាម្ចាស់កម្មសិទ្ធិពេញច្បាប់ ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលមានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៨.-**

បុគ្គលិករបស់ រ ស ស ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែក អនុម័តដោយក្រុមប្រឹក្សាភិបាល ។

នៅពេលមិនទាន់មានលក្ខន្តិកៈដោយឡែកនេះ ក្រុមប្រឹក្សាភិបាល រ ស ស ត្រូវសម្រេចអំពីអន្តរវិធានដែលទាក់ទងនឹងបញ្ហានេះនៅក្នុងកិច្ចប្រជុំលើកទី១របស់ខ្លួន ដើម្បីឱ្យសហគ្រាសអាចដំណើរការបានល្អ ។

ចាប់ពីពេលដែលលក្ខន្តិកៈដោយឡែកនេះចូលជាធរមាន បុគ្គលិករបស់ រ ស ស លែងមានលក្ខណៈសម្បត្តិជាមន្ត្រីរាជការរបស់រដ្ឋតទៅទៀត។

## ជំពូកទី ២
## របនាសម្ព័ន្ធផ្នែករដ្ឋបាល

**មាត្រា ៩.-**

រ ស ស ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពដូចខាងក្រោមនេះ ÷

- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ១ រូប ប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
- តំណាងសាលាខេត្តសៀមរាប ១ រូប សមាជិក
- តំណាងអាជ្ញាធរអប្សរា ១ រូប សមាជិក
- តំណាងនិយោជិតរបស់ រ ស ស ១ រូប សមាជិក
- អគ្គនាយក រ ស ស ១ រូប សមាជិក

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។ តំណាងនិយោជិត ត្រូវបានជ្រើសតាំងដោយមានការបោះឆ្នោតក្នុងចំណោមនិយោជិត របស់ រ ស ស ។

**មាត្រា ១០.-**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានសញ្ជាតិខ្មែរ មានសិទ្ធិពលរដ្ឋពេញលេញ និងពុំដែលទទួលទណ្ឌកម្ម ពីបទមជ្ឈិម ឡើងទៅ ។

សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់នោះត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីរាជការសកម្មដែលបានបម្រើការយ៉ាងតិច ៥ឆ្នាំ ឬអ្នកចូលនិវត្ត ដែលមានអាយុមិនលើសពី ៦៥ឆ្នាំ ឬឥស្សរជនខ្មែរ ដែលមានសមត្ថភាពខាងវិស័យសេដ្ឋកិច្ច ខាងនីតិសាស្ត្រ ឬ ខាងវិទ្យាសាស្ត្រ ។

អាណត្តិសមាជិកក្រុមប្រឹក្សាភិបាលមានថិរវេលា ៣ឆ្នាំ ហើយអាណត្តិនេះអាចបន្តជាថ្មីទៀតបាន ។

**មាត្រា ១១.-**

ក្រុមប្រឹក្សាភិបាលកំណត់ទិសដៅ និងត្រួតពិនិត្យការគ្រប់គ្រង រ ស ស ព្រមទាំងធានាសនិទានភាព និងប្រសិទ្ធភាពនៃការរៀបចំ និងការប្រព្រឹត្តិទៅរបស់ រ ស ស ។ ដើម្បីបំពេញមុខងារនេះ ក្រុមប្រឹក្សាភិបាលមាន ភារកិច្ច ជាអាទិ៍ ដូចតទៅ ÷

១) ផ្តល់ការយល់ព្រម លើគម្រោងសហគ្រាស ដូចមានចែងនៅក្នុងមាត្រា ២០ នៃអនុក្រឹត្យនេះ ។

២) វាយតម្លៃក្នុងចន្លោះពេលមួយទៀងទាត់នូវលទ្ធផលដែលសម្រេចបាន និង លើកវិធានការកែតម្រូវសម្រាប់ អនុវត្ត ។

៣) ផ្តល់ការយល់ព្រមលើតុល្យការ និងគណនីប្រចាំឆ្នាំព្រមទាំងលើរបាយការណ៍សកម្មភាពរបស់សហគ្រាស ។

៤) សម្រេចតាមសំណើរបស់អគ្គនាយកនូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និង កាំប្រាក់បៀវត្សរ៍សម្រាប់បុគ្គលិក ដោយគោរពច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។

៥) ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងកិច្ចព្រមព្រៀង ដែល រ ស ស ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និង បែបបទ ដូចមានចែងក្នុងបទបញ្ជាស្តីពី កិច្ចសន្យា និងកិច្ចព្រមព្រៀងដែលចុះហត្ថលេខាដោយសហគ្រាសសាធារណៈ ។

៦) អនុញ្ញាតឱ្យលក់ ទិញ ដូរ ជួលអចលនទ្រព្យគ្រប់ប្រភេទ ឬភាគហ៊ុន ព្រមទាំងអនុញ្ញាតការខ្ចីបុល រយៈពេលមធ្យម ឬ វែង របស់ រ ស ស ស្របតាមច្បាប់ និងបទបញ្ជាទាំងឡាយជាធរមាន ។

៧) សម្រេចលើលទ្ធកម្មតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមានស្តីពី លទ្ធកម្មសាធារណៈ ។

៨) សម្រេចបង្កើតបើក បិទការិយាល័យ និងទីភ្នាក់ងាររបស់ រ ស ស គ្រប់ទីកន្លែងតាមការវិនិច្ឆ័យ របស់ខ្លួន ។

**មាត្រា ១២.** -

ក្រុមប្រឹក្សាភិបាលបើកការប្រជុំគ្រប់ពេល អាស្រ័យលើអត្ថប្រយោជន៍នៃសហគ្រាសតាមការអញ្ជើញរបស់ ប្រធាន ឬ តាមសំណើនៃសមាជិក ដែលមានចំនួនភាគច្រើនក្នុងបណ្តាសមាជិកទាំងអស់ ។ ក្រុមប្រឹក្សាភិបាលត្រូវប្រជុំ យ៉ាងតិចមួយដង ក្នុងរៀងរាល់៣ខែ ។

ក្នុងករណីប្រធានមានធុរៈ ប្រធានត្រូវជ្រើសរើសសមាជិកម្នាក់ក្នុងបណ្តាសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់សម្រាប់បំពេញ ភារកិច្ចជំនួសប្រធានជាបណ្តោះអាសន្ន ។

ក្រុមប្រឹក្សាភិបាលពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌនៃតួនាទីរបស់ខ្លួន ។ របៀបវារៈនៃកិច្ចប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើទៅជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបានយ៉ាងតិច១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តបាន លុះត្រាតែចំនួនសមាជិកវត្តមានក្នុងសម័យប្រជុំនោះមាន ចំនួនយ៉ាង តិច ០៤នាក់ នៃបណ្តាសមាជិកទាំងអស់ ។ ប្រសិនបើចំនួនកូរ៉ុមមិនបានគ្រប់ទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំជាថ្មីម្តង ទៀតក្នុងរយៈពេល ១៥ថ្ងៃ ក្រោយ ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះមិន ទាមទារកូរ៉ុមទេ ។

សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសម្លេងភាគ ច្រើននៃសមាជិកវត្តមាននៅក្នុងអង្គប្រជុំ ។ ប្រសិនបើការបែកសម្លេងមានចំនួនស្មើ សម្លេងប្រធានក្រុមប្រឹក្សាភិបាលឬប្រធាន អង្គប្រជុំ ត្រូវចាត់ទុកថា មានឧត្តមានុភាព ។

**មាត្រា ១៣.** -

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយដែលត្រូវបញ្ជូនទៅក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និង មន្ត្រីត្រួតពិនិត្យរដ្ឋ និង គោលដៅដទៃទៀត ដែលមានចែងក្នុងមាត្រា ២៦ នៃអនុក្រឹត្យនេះ ក្នុងរវាង ១៥ថ្ងៃ យ៉ាងយូរ ចាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុនៃកិច្ចប្រជុំ ត្រូវទទួលការយល់ព្រមពីក្រុមប្រឹក្សាភិបាលនាសម័យប្រជុំលើកក្រោយ ហើយត្រូវចម្លងចូលបញ្ជីដែលមានលេខរៀងទំព័រជាហូរហែរ និងមានហត្ថលេខាចំណាំត្រឹមត្រូវ ។ កំណត់ហេតុដើមត្រូវបានចុះ ហត្ថលេខាដោយប្រធាននៃអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលមានវត្តមានក្នុងកិច្ចប្រជុំពេលមុននោះ ។

**មាត្រា ១៤.** -

អគ្គនាយកជាអ្នកគ្រប់គ្រងប្រក្រតីនៃ រ ស ស ។ អគ្គនាយកនេះត្រូវតែងតាំងសម្រាប់ អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ១៥.** -

ក្រុមប្រឹក្សាភិបាលប្រគល់ជូនអគ្គនាយកនូវអំណាចចាំបាច់សម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ដឹកនាំសហគ្រាស ស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះ អគ្គនាយកត្រូវ ÷

១-រៀបចំសំណុំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល និងជាអ្នកចាត់ចែងការអនុវត្តនីរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមដំណាក់កាលនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាព របស់ រ ស ស ។

២-ទទួលបន្ទុកដឹកនាំ រ ស ស ផ្នែកបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុ ។

៣-តំណាង រ ស ស ចំពោះមុខអតិថិជន ស្ថាប័នរដ្ឋ និងឯកជន ចំពោះមុខតុលាការ និងអាជ្ញាធរ ទាំងឡាយដែលពាក់ព័ន្ធ ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬ បញ្ឈប់ពីការងារ បញ្ជាភ្នាក់ងារ ឬ បុគ្គលិកគ្រប់រូបដែលជានិយោជិករបស់ រ ស ស ដោយគោរពតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល លក្ខន្តិកៈបុគ្គលិកច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅឱ្យមន្ត្រី ដែលធ្វើការក្រោមឱវាទខ្លួនស្របតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦- អនុវត្តនូវគ្រប់ភារកិច្ចផ្សេងៗ ទៀត ដែលក្រុមប្រឹក្សាភិបាលប្រគល់ឱ្យ ។

**មាត្រា ១៦. –**

លាភការរបស់អគ្គនាយក និងប្រាក់បំណាច់សម្រាប់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដោយក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៧. –**

ការចុះកិច្ចសន្យា និងការអនុវត្តនីកិច្ចសន្យាដោយ រ ស ស ត្រូវគោរពតាមបែបបទ និងនីតិវិធី ដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូកទី ៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៨. –**

រ ស ស កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ការិយបរិច្ឆេទគណនេយ្យ ចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែ ធ្នូ នៃឆ្នាំដដែល ។

ប្រធានគណនេយ្យត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើ របស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍គណនេយ្យ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាភិបាលមុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ ( ឆ្នាំបិទការិយបរិច្ឆេទ ) ផ្អែកលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនី ត្រូវដាក់សុំការយល់ព្រមពីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួច លើឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ក៏ត្រូវបញ្ជូនទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ផងដែរ ដើម្បីសុំមតិតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃច្បាប់ស្តីពី លក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

**មាត្រា ១៩. –**

ស្នងការគណនីត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិ ២ឆ្នាំ ។ អាណត្តិនេះអាចបន្តទៀតបាន ។ ប្រាក់បំណាច់សម្រាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ហើយត្រូវចាត់ទុកជាចំណាយអាជីវកម្មរបស់ រ ស ស ។

ស្នងការគណនីត្រូវធ្វើរបាយការណ៍មួយដើម្បីបញ្ជាក់ថា គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុ និងបេតិកភ័ណ្ឌរបស់ រ ស ស ។ នៅគ្រប់វេលា ស្នងការគណនីអាចធ្វើការផែកឆេរ និងការត្រួតពិនិត្យដែលខ្លួនយល់ថាចាំបាច់គួរតែត្រួតពិនិត្យថែមទាំងអាចទារឯកសារ និងបញ្ជីគណនេយ្យគ្រប់យ៉ាងសម្រាប់ធ្វើការត្រួតពិនិត្យ ។ បើការពិនិត្យស្រាវជ្រាវនេះបង្ហាញឱ្យឃើញភាពមិនត្រឹមត្រូវណាមួយ ស្នងការគណនីត្រូវរាយការណ៍ភ្លាមជូនប្រធានក្រុមប្រឹក្សាភិបាល ។

បេសកកម្មរបស់ស្នងការគណនី ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ៤២ អនក្រ បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពី ស្នងការគណនីនៃសហគ្រាសសាធារណៈ ។

ស្នងការគណនីអាចចូលប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមសេចក្តីអញ្ជើញនៃប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា ២០. -**

រៀងរាល់ឆ្នាំមុនថ្ងៃទី ០១ ខែ តុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគម្រោងសហគ្រាសប្រចាំឆ្នាំ តាមសំណើរបស់អគ្គនាយក។ ឯកសារទាំងនេះ ត្រូវទទួលការយល់ព្រមពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលយ៉ាងយូរពីរ (២) ខែ ចាប់ពីថ្ងៃដែលឯកសារបានមកដល់ ក្រសួងទាំងពីរ ។

គម្រោងសហគ្រាសនេះ ត្រូវបញ្ជាក់នូវ÷

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបម្រុងសម្រាប់សម្រេចកម្មវិធីវិនិយោគនេះ

២- ថវិកាសម្រាប់ដំណើរការនៃសហគ្រាស

៣- ថ្លៃសេវាកម្មផ្សេងៗ របស់ រ ស ស ទៅអតិថិជន ដើម្បីសហគ្រាសអាចមានលទ្ធភាពទប់ទល់ និង សោហ៊ុយដែលមានគិតបញ្ចូលនូវប្រាក់រំលស់ទុនវិនិយោគ និងអាចធានាសមតាហិរញ្ញវត្ថុរបស់ខ្លួនបាន ។

៤- លក្ខណៈវិនិច្ឆ័យសម្រាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ រ ស ស ។

៥- វិភាគទានទាំងឡាយដែលរដ្ឋអាចផ្តល់ជូន រ ស ស ដើម្បីជ្រោមជ្រែងការបង់ខាតចំពោះសេវា សាធារណៈដែលសហគ្រាស បានផ្តល់សម្រាប់បម្រើអត្ថប្រយោជន៍របស់ពលរដ្ឋ ។

**មាត្រា ២១. -**

ធនធាននៃ រ ស ស ជាអាទិ៍មាន ÷

- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យ
- វិភាគទាន ឬ ប្រាក់ឧបត្ថម្ភដែលបានមកពីរដ្ឋ សមូហភាពសាធារណៈ និងសហគមន៍អន្តរជាតិ
- ប្រាក់ឧបត្ថម្ភដែលបានមកពីវិភាគទាន អំណោយ ឬកេរ្តិ៍មតិកឯកជន ដោយមានការទទួលព្រមព្រៀងជា មុនពីក្រុមប្រឹក្សាភិបាល

- ប្រាក់ខ្ចីបុល
- ប្រាក់បានមកពីការលក់ ការដោះដូរ ឬការជួលទ្រព្យចលនវត្ថុ ឬអចលនវត្ថុ
- ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទ បានមកពីសកម្មភាពសហគ្រាស ។

**មាត្រា ២២.** -

ចំណាយនៃ រ ស ស ជារួមមាន :

- ចំណាយប្រក្រតី សម្រាប់ដំណើរការ
- ចំណាយវិនិយោគ សាងសង់ និងជួសជុល
- សំណងបំណុល
- សោហ៊ុយផ្សេងៗ ដែល រ ស ស ត្រូវចំណាយដើម្បីបំពេញបេសកកម្មរបស់ខ្លួន ។

**មាត្រា ២៣.** -

រ ស ស អាចមានគណនីចរន្តក្នុងធនាគារពាណិជ្ជផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សម្រាប់តម្រូវការ របស់ខ្លួន ។

**មាត្រា ២៤.** -

ក្នុងរយៈពេល ៥ឆ្នាំ ឬ លើសពីនេះ ប្រាក់ចំណេញដែល រ ស ស ទទួលបានក្រោយពីការទូទាត់ស្របតាមវិធានគណនេយ្យ ត្រូវបង់មួយភាគ ឬទាំងអស់ ឬរក្សាទុកឱ្យសហគ្រាសទាំងអស់ សម្រាប់ធ្វើការអភិវឌ្ឍន៍ចាំបាច់ផ្សេងៗ តាមការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ២៥.**

ការខ្ចីបុលរយៈពេលមធ្យម ឬ វែង ដោយ រ ស ស សម្រាប់ប្រើប្រាស់លើចំណាយវិនិយោគ ត្រូវមានការយល់ព្រមជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## ទំនាក់ទំនងជាមួយរដ្ឋ និងអតិថិជន

**មាត្រា ២៦.** -

រយៈពេល ១៥ថ្ងៃ យ៉ាងយូរបំផុត ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល រ ស ស ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចខាង

ក្រោមនេះ ៖

- កំណត់ហេតុនៃកិច្ចប្រជុំនីមួយៗ របស់ក្រុមប្រឹក្សាភិបាល
- គម្រោងសហគ្រាសដូចមានចែងក្នុងមាត្រា ២០ នៃអនុក្រឹត្យនេះ
- របាយការណ៍ស្តីពី សកម្មភាព តុល្យការ និងគណនីគ្រប់គ្រង ទាំងឡាយនៃ **រ ល ស**
- របាយការណ៍ស្តីពី លទ្ធផលនៃការត្រួតពិនិត្យរបស់ស្នងការគណនី ។

**មាត្រា ២៧:** -

ត្រូវបានដាក់ឱ្យនៅអម រ ស ស នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ ចំណុចដែលមានក្នុងរបៀបវារៈតែពុំមានសម្លេងឆ្នោតទេ ។ មន្ត្រីត្រួតពិនិត្យរដ្ឋបំពេញសកម្មភាពរបស់ខ្លួន អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា២០ ទៅ ២៥ នៃច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា ២៨.** -

រ ស ស មានសិទ្ធិផ្អាក ឬផ្តាច់ការផ្គត់ផ្គង់ទឹកស្អាត ឬសេវាដទៃទៀត ចំពោះអតិថិជន ឯកជន ឬអង្គភាពសាធារណៈណាមួយដែលមិនបង់ថ្លៃទឹកឱ្យ រ ស ស ក្នុងរយៈពេលវេលា ដែលបានកំណត់ក្នុងកិច្ចសន្យាជាវទឹក ក្រោយពីបានធ្វើការសម្របសម្រួលសមស្រប ។ ការសម្របសម្រួលត្រូវធ្វើឡើង តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរចំនួនបីដងក្នុងរយៈពេលបីសប្តាហ៍ ។

**មាត្រា ២៩.** -

ទំនាក់ទំនងរវាង រ ស ស និងអតិថិជន ព្រមទាំងអំពើល្មើសច្បាប់ទាំងឡាយពីសំណាក់អតិថិជន ដែលប៉ះពាល់ដល់សហគ្រាស ជាពិសេសការបំបាត់បរិមាណទឹកដែលត្រូវបានប្រើប្រាស់ ការបំផ្លិចបំផ្លាញ ឬ ការកេងប្រវ័ញ្ច វត្ថុដែលជាកម្មសិទ្ធិរបស់ រ ស ស ការតបណ្តាញទឹកដោយគ្មានការអនុញ្ញាត ។ល។ ត្រូវស្ថិតនៅក្រោមច្បាប់ និងបទបញ្ជា ទាំងឡាយជាធរមាន ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ៣០.** -

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣១.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អភិបាលខេត្តសៀមរាប ប្រធានអាជ្ញាធរអប្សរា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ